ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១៥-៧៣៥ ឥ.ជ.ព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពីការផ្អាកទទួលពាក្យស្នើសុំចុះបញ្ជីរបស់ប្រតិបត្តិករឥណទានជនបទ

យោងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសលេខធ៧-០២-៤៩ ប្រ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចចុះបញ្ជីប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងការសុំអាជ្ញាបណ្ណរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអនុលោមតាមសេចក្តីថ្លែងការណ៍រួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី មេត្តាជ្រាបថាគិតត្រឹមខែកញ្ញា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជា បានទទួលពាក្យស្នើសុំចុះបញ្ជីរបស់ប្រតិបត្តិករឥណទានជនបទចំនួនជិត ៣០០ ។ ពាក្យសុំទាំងនេះកំពុងរៀបចំពិនិត្យ និងវាយតម្លៃស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។ ដើម្បីបំពេញការងារនេះឲ្យបានសុក្រិត្យ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ធនាគារជាតិនៃកម្ពុជា ចាំបាច់ត្រូវការពេលវេលា និងធនធានសមស្របដើម្បីវាយតម្លៃ និងត្រួតពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយលើពាក្យសុំនីមួយៗ ព្រមទាំងកែសម្រួលបទប្បញ្ញត្តិដែលចាំបាច់មួយចំនួនផង ។ អាស្រ័យហេតុនេះ ធនាគារជាតិនៃកម្ពុជាសម្រេចផ្អាកជាបណ្តោះអាសន្នក្នុងការទទួលពាក្យស្នើសុំរបស់ប្រតិបត្តិករឥណទានជនបទ ចាប់ពីថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៥ នេះតទៅ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន និងមានកិច្ចសហការខ្ពស់ ។

ទេសាភិបាល

ជា.ចាន់តូ